# ការយល់ព្រមចំពោះការវាយតម្លៃរបស់ឪពុកម្តាយ

បទបញ្ញត្តិអប់រំពិសេសយូទីហ្វាយរបស់រដ្ឋមេអ៊ីន (MUSER) V.1.A.(4)(i) & B.(3)(a)(i)

| | |
|---|---|
| កាលបរិច្ឆេទប្រគល់/ផ្ញើជូនឪពុកម្តាយ : | |
| កាលបរិច្ឆេទទូលពីឪពុកម្តាយត្រលប់មកវិញ : | |

កាលបរិច្ឆេទកំណត់នៃកិច្ចប្រជុំស្តីពីសិទ្ធិទទួលបានរបស់ក្រុមការងារ IEP (45 ថ្ងៃសិក្សាបន្ទាប់ពីការទទួលបានការយល់ព្រម)

កាលបរិច្ឆេទកំណត់នៃកិច្ចប្រជុំស្តីពីសិទ្ធិទទួលបានរបស់ក្រុមការងារ IFSP និងការអភិវឌ្ឍន៍នៃ IFSP (45 ថ្ងៃប្រតិទិនគិតពីកាលបរិច្ឆេទនៃការបញ្ជូនទៅកាន់ទីតាំងរបស់ CDS )

**ការដាក់ឱ្យនៅ SAU / សាលា / ថ្នាក់ ឬ CDS :**

ឈ្មោះកូន :
ថ្ងៃ.ខែ.ឆ្នាំកំណើត/អាយុ :
ព័ត៌មានឪពុកម្តាយ :
អ្នកគ្រប់គ្រងសំណុំរឿង :

**<u>គោលបំណងនៃការវាយតម្លៃ :</u>**

☐ ការវាយតម្លៃបឋម ☐ ការវាយតម្លៃឡើងវិញ * ☐ ផ្សេងៗ

ខាងក្រោមនេះ គឺជាការរៀបរាប់អំពីការវាយតម្លៃដែលត្រូវបានផ្តល់ជាអនុសាសន៍សម្រាប់សិស្សដែលមានឈ្មោះខាងលើ ។ ឪពុកម្តាយ/សិស្សពេញវ័យ នឹងត្រូវបានផ្តល់ឱ្យនូវសំណៅចម្លងនៃរបាយការណ៍វាយតម្លៃយ៉ាងហោចណាស់បីថ្ងៃ មុនកិច្ចប្រជុំកម្មវិធីអប់រំផ្ទាល់ខ្លួន (Individual Educational Program) [IEP] ឬកិច្ចប្រជុំផែនការសេវាកម្មគ្រួសារផ្ទាល់ខ្លួន (Individual Family Service Plan) [IFSP] ។ នៅក្នុងកិច្ចប្រជុំ IEP/IFSP យើងខ្ញុំនឹងពន្យល់អំពីលទ្ធផលនៃការវាយតម្លៃ រួចហើយកំណត់ថាតើកុមារមានសិទ្ធិទទួលបាន ឬនៅតែមានសិទ្ធិទទួលបានសេវាកម្មអប់រំពិសេស ដូចកុមារដែលមានពិការភាពដែរឬទេ ។ ប្រសិនបើអ្នកមានសំណួរណាមួយអំពីនីតិវិធីទាំងនេះ សូមទូរស័ព្ទមក តាមរយៈលេខ ហើយយើងខ្ញុំនឹងពិភាក្សាជាមួយអ្នកអំពីបញ្ហានេះ ។

សមាជិកក្រុមការងារ IEP/IFSP ដែលបានគូសយកខាងក្រោម បានផ្តល់នូវព័ត៌មានទាក់ទងទៅនឹងទិន្នន័យបន្ថែមដែលចាំបាច់ដើម្បីជួយក្នុងការកំណត់ថាតើកូនរបស់អ្នក គឺជាកុមារដែលមានពិការភាពដែរឬទេ មានតម្រូវការអប់រំរបស់កូនអ្នកដែរឬទេ ហើយប្រសិនបើមានការវាយតម្លៃឡើងវិញ ថាតើកូនរបស់អ្នកនៅតែបន្តមានពិការភាព និងមានតម្រូវការអប់រំដែរឬទេ។ (MUSER V.3.A.)

**<u>គូសយក និងចុះកាលបរិច្ឆេទ</u>**

**សមាជិកក្រុមការងារ IEP / IFSP** **កាលបរិច្ឆេទដែលព័ត៌មានត្រូវបានផ្តល់ឱ្យ :**

☐ ឪពុកម្តាយ
☐ គ្រូបង្រៀនពិសេស
☐ មន្ត្រីរដ្ឋបាល
☐ គ្រូបង្រៀនជាប្រចាំ
☐ អ្នកគ្រប់គ្រងសំណុំរឿងរបស់ CDS
☐ អ្នកវាយតម្លៃរបស់ CDS
☐ ផ្សេងៗ (តួនាទី)

**<u>ការរៀបរាប់អំពីការវាយតម្លៃ :</u>**

1. ☐ **<u>ការធ្វើតេស្តទៅលើការសិក្សា/ការអភិវឌ្ឍន៍</u>** ត្រូវបានរៀបចំឡើងដើម្បីកំណត់ថាតើការរីកចម្រើនផ្នែកការសិក្សា/ការអភិវឌ្ឍន៍របស់សិស្ស ស្ថិតនៅក្នុងវិស័យសិក្សាជាក់លាក់មួយណាដូចជា ការអភិវឌ្ឍន៍ទូទៅ ការអាន គណិតវិទ្យា និងការប្រកបអក្សរ ។ លទ្ធផលនៃការសិក្សា និងការអភិវឌ្ឍន៍របស់សិស្ស នឹងត្រូវបានប្រៀបធៀបជាមួយនឹងលទ្ធផលរបស់សិស្សនៅក្នុងសាលានេះ និងរបស់សិស្សនៅទូទាំងប្រទេស ។

2. ☐ **<u>ការធ្វើតេស្តប្រាជ្ញា</u>** ជាប់ទាក់ទងនឹងការគ្រប់គ្រងផ្ទាល់ខ្លួននូវតេស្តវាស់វែងប្រាជ្ញា ។ តេស្តទាំងនេះ ត្រូវបានរៀបចំឡើងដើម្បីវាស់វែងសមត្ថភាពផ្សេងគ្នាជាច្រើនប្រភេទ ដូចជា អ្វីដែលសិស្សអាចធ្វើបាន និងថាតើពួកគេធ្វើដោយរបៀបណា ។

3. ☐ **<u>ការសង្កេត</u>** ត្រូវបានធ្វើឡើងនៅក្នុងបរិយាកាសសិក្សារបស់កុមារ (រួមទាំងនៅក្នុងថ្នាក់រៀនធម្មតា) ដើម្បីកត់ត្រាទុកទៅលើលទ្ធផលនៃការសិក្សា និងអាកប្បកិរិយារបស់កុមារនៅក្នុងវិស័យលំបាកៗ ។

4. ☐ **ការធ្វើតេស្តិ៍ទៅលើការអភិវឌ្ឍន៍ការសិក្សា** ត្រូវបានរៀបចំឡើងដើម្បីកំណត់ថាតើ ចំណុចខ្លាំង និងចំណុចខ្សោយរបស់សិស្សមានអ្វីខ្លះ ពាក់ព័ន្ធទៅនឹងការវិភាគព័ត៌មាន ។

5. ☐ **ការធ្វើតេស្តិ៍លើការនិយាយ/ភាសា** ត្រូវបានរៀបចំឡើងដើម្បីកំណត់ពីជំនាញទំនាក់ទំនងរបស់សិស្សតាមរយៈការនិយាយស្តី សម្លេង ភាពស្ទាត់ជំនាញ ភាសាបង្ហាញពីគំនិត ឬអារម្មណ៍ និងភាសាបង្ហាញពីការទទួលយក ។

6. ☐ **ការវាយតម្លៃចិត្តសាស្ត្រ** ត្រូវបានរៀបចំឡើងដើម្បីវាយតម្លៃទៅលើបុគ្គលិកលក្ខណៈ និង/ឬការប្រព្រឹត្តិនៃអាកប្បកិរិយា ។វិធីសាស្ត្រវាយតម្លៃដែលបានប្រើជាទូទៅរួមមាន ការសម្ភាសន៍ជាមួយឪពុកម្តាយ និងកុមារ កំណត់ត្រាបុគ្គលិកលក្ខណៈ មាត្រដ្ឋានចំណាត់ថ្នាក់អាកប្បកិរិយា និងតេស្តិ៍ប៉ាន់ស្មាន។

7. ☐ **ការវាយតម្លៃព្យាបាលរូបរាងកាយ** វាយតម្លៃលើការអភិវឌ្ឍចលនាដ៏ធំរបស់សិស្ស ។ ការវាយតម្លៃរួមមានតែមិនកំណត់ លំដាប់ចលនា ការវាយតម្លៃលើសាច់ដុំដៃ ការអនុវត្តជំនាញជាក់ស្តែង ការបត់បែនតាមបរិយាកាស ការអភិវឌ្ឍន៍ការបញ្ចូលគំនិតបត់បែន ការវាយតម្លៃគុណភាពសាច់ដុំ ជំនាញចលនាសរុប (ឧទាហរណ៍ តុល្យភាព ការសម្របសម្រួល ការគិតឆាប់រហ័ស ការដុសខាត់ជំនាញ) និងការត្រួតពិនិត្យតម្រូវការឧបករណ៍ណាមួយដែលសិស្សអាចមាន ។

8. ☐ **ការវាយតម្លៃព្យាបាលការងារ** ផ្តោតទៅលើតម្រូវការមុខងាររបស់សិស្សទាក់ទងទៅនឹង តែមិនកំណត់ចំពោះការអនុវត្ត : ជំនាញក្នុងការជួយខ្លួនឯង អាកប្បកិរិយា និងការលេងសើចបត់បែន ការអភិវឌ្ឍន៍ និងការប្រមូលផ្តុំវិញ្ញាណ ការអភិវឌ្ឍន៍ និងការប្រមូលផ្តុំចលនា និងឬកពា ។

9. ☐ **ការវាយតម្លៃសម្បទា និងការចាប់អារម្មណ៍** ត្រូវបានរៀបចំឡើងដើម្បីកំណត់លើចំណុចខ្លាំង ចំណុចខ្សោយ និងការចាប់អារម្មណ៍ ដោយសារពួកវាទាក់ទងនឹងការរៀបចំ និងការជ្រើសរើសវិជ្ជាជីវៈ ។

10. ☐ **ការវាយតម្លៃបន្ថែម** ត្រូវបានរៀបចំឡើងដើម្បីប្រមូលព័ត៌មានសំខាន់ៗអំពីសុខភាព ប្រវត្តិសង្គម ឬការអភិវឌ្ឍន៍ អាកប្បកិរិយា (អាចបំពេញបានដោយការសម្ភាសន៍ជាមួយនឹងឪពុកម្តាយ បុគ្គលិកសាលា ឬកុមារ) ឬការវាយតម្លៃលើវិញ្ញាណក្នុងការមើល និងការស្តាប់ ។

11. ☐ **ផ្សេងៗ**

ខ្ញុំយល់អំពីសញ្ញាណ និងមូលហេតុចំពោះការវាយតម្លៃដូចដែលបង្ហាញមកពីខាងលើ ក៏ដូចជាសេចក្តីថ្លែងការណ៍អំពីការរក្សាឱ្យមានសុវត្ថិភាពលើនីតិវិធីដែលមានភ្ជាប់មកជាមួយនឹងទម្រង់បែបបទយល់ព្រមនេះ ប្រសិនបើនេះជាការបញ្ជូនបឋម ឬតាមសំណើសុំការវាយតម្លៃរបស់ឪពុកម្តាយ (MUSER II.6.) ។ ខ្ញុំថែមទាំងយល់ទៀតថា ការយល់ព្រមរបស់ខ្ញុំ គឺជាការស្ម័គ្រចិត្ត និងអាចត្រូវបានបដិសេធ (ដកយកវិញ) នៅពេលណាមួយក៏បាន ។ សេកសិន II.6.B. នៃ MUSER ពន្យល់អំពីទស្សនៈទាននៃការបដិសេធការយល់ព្រមកាន់តែលំអិតជាងនេះទៀត ។ ប្រសិនបើខ្ញុំបដិសេធការយល់ព្រម នោះក្រុមការងារ IEP/IFSP នឹងធ្វើការកោះប្រជុំ និងពិចារណាទៅលើការបដិសេធ (ដកយកវិញ) របស់ខ្ញុំ ។ ប្រសិនបើក្រុមការងារ IEP/IFSP មិនយល់ស្របជាមួយនឹងការបដិសេធទាក់ទងនឹងការវាយតម្លៃបឋម នោះអង្គភាពរដ្ឋបាលរបស់សាលា អាចប្រើប្រាស់ដំណើរការមជ្ឈត្តកម្ម ឬក៏រៀបចំឱ្យមានជាសវនាការជំទាស់ទៅនឹងការបដិសេធនូវការយល់ព្រមរបស់ខ្ញុំ ។

* SAU នឹងទទួលបាននូវការជូនដំណឹងពីការយល់ព្រមជាលាយលក្ខណ៍អក្សររបស់ខ្ញុំ មុននឹងធ្វើការវាយតម្លៃឡើងវិញទៅលើកូនរបស់ខ្ញុំដែលមានពិការភាព លើកលែងតែក្នុងករណីដែល SAU អាចបង្ហាញថា ខ្លួនបានចាត់វិធានការន៍សមស្របដើម្បីទទួលបានការយល់ព្រមនោះ ហើយខ្ញុំមិនបានឆ្លើយតបវិញ ។

**សូមគូសយកនៅក្នុងប្រអប់ដែលសមស្រប និងចុះហត្ថលេខាខាងក្រោម ។**

☐ **យល់ព្រម :** ខ្ញុំពិតជាផ្តល់ការយល់ព្រមរបស់ខ្ញុំចំពោះការវាយតម្លៃបែបនេះមែន ។

☐ **បដិសេធ :** ខ្ញុំមិនចង់ឱ្យកូនរបស់ខ្ញុំត្រូវទទួលការវាយតម្លៃដូចបានរៀបរាប់ខាងលើនេះទេ ។

______________________________ ______________________________

ហត្ថលេខាឪពុកម្តាយ/អាណាព្យាបាល កាលបរិច្ឆេទ

ឯកសារភ្ជាប់ អាចនឹងត្រូវបានភ្ជាប់មកជាមួយឯកសារនេះ ហើយអាចនឹងត្រូវបានកត់ត្រាទុកដូចខាងក្រោមផងដែរ ។

កែប្រែឡើងវិញនៅថ្ងៃទី 08/10/2009